00754050

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

E138/1/2/1

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៩)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(09)

| | |
|---|---|
| នៅចំពោះមុខ: | ចៅក្រម គង់ ស្រីម ប្រធាន |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១១ |
| ភាសា: | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 11 / 2011
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

# ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកសេចក្តីសម្រេចដោះលែងជនជាប់ចោទ

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ**
អៀង ធីរិទ្ធ
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
Michiel PESTMAN
Victor KOPPE

សុន អរុណ
អាង ឧត្ដម
Mich G.KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS, QC
ស សុវាន
Jacques VERGES

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖

**កត់សម្គាល់** សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ("ដីកាបង្គាប់ឲ្យដោះលែង")[1] ។

**ទទួលបាន** សំណើរបស់សហព្រះរាជអាជ្ញាដោយអនុលោមតាមវិធាន៨២(៦)នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៨) សុំផ្អាកសេចក្ដីសម្រេចបង្គាប់ឲ្យដោះលែង ("សំណើសុំ")[2] ដោយភ្ជាប់ជាមួយនឹងឯកសារថតចម្លងនៃការដាក់ពាក្យបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចបង្គាប់ដោះលែង ("បណ្ដឹងសាទុក្ខ")[3] ។

**ដោយពិចារណាលើ** ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើជនជាប់ចោទ អៀង ធីរិទ្ធ និងការខ្វែងយោបល់គ្នារវាងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងលើបញ្ហានៃការដាក់លក្ខខណ្ឌក្រោយធ្វើការដោះលែង និងដោយហេតុថាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា មានមូលដ្ឋានច្បាស់លាស់ ។

**ដោយអនុលោមតាម** វិធាន៨២(៦)នៃវិធានផ្ទៃក្នុង ។

**សម្រេច:**

**ទទួលយក** សំណើរបស់សហព្រះរាជអាជ្ញា ។

**បង្គាប់** ឲ្យផ្អាកសេចក្ដីសម្រេចដែលបង្គាប់ឲ្យដោះលែងរបស់អង្គជំនុំជម្រះសាលាដំបូង និង

**បង្គាប់ថា** ជនជាប់ចោទត្រូវស្ថិតក្នុងមន្ទីរឃុំឃាំងរហូតដល់ពេលអង្គជំនុំជម្រះតុលាការកំពូល ចេញសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

E.C.C.C * C.E.T.C * SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

**គង់ ស្រ៊ីម**

[1] សេចក្ដីសម្រេចលើសម្បទារបស់អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ, E138 ។

[2] សំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ E138/1/2 ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១១។

[3] បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ E138/1/1 ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ។